# កត្តាដែលនាំឱ្យរីកចម្រើនសេដ្ឋកិច្ចចិន

ដោយ **ជឹម សុជាតិ** មន្ត្រី នៃមជ្ឈមណ្ឌលសិក្សាចិន



## ១- សេចក្តីផ្តើម

ក្រោយពីកំណែទម្រង់របស់លោក តេង សៀវពីង ក្នុងឆ្នាំ១៩៧៨មក ប្រទេសចិនបានអភិវឌ្ឍសេដ្ឋកិច្ចរបស់ខ្លួនក្លាយជាមហាអំណាចសេដ្ឋកិច្ចលេខ២ក្នុងពិភពលោក។ អត្ថបទនេះនឹងសិក្សាអំពីការរីកចម្រើនសេដ្ឋកិច្ចរបស់ចិននាពេលសព្វថ្ងៃនេះ និងកត្តាដែលនាឱ្យមានការរីកចម្រើនសេដ្ឋកិច្ចបែបនេះ។ កត្តាដែលនាំឱ្យសេដ្ឋកិច្ចចិនមានការរីកចម្រើនគឺដោយសារកំណែទម្រង់សេដ្ឋកិច្ច និងការវិនិយោគចូលក្នុងសេដ្ឋកិច្ចគួបផ្សំការកើនឡើងផលិតភាពរបស់ចិន (Productivity)។

## ២- កត្តាកំណើនសេដ្ឋកិច្ចចិន

### ២.១- កំណែទម្រង់សេដ្ឋកិច្ចរបស់ចិនមុនឆ្នាំ២០១២

ភាពជោគជ័យនៃកំណែទម្រង់របស់ចិនត្រូវបានវាស់វែងការរីកលូតលាស់នៃសេដ្ឋកិច្ចដែលមានកំណើនខ្ពស់ (G. Chow, ២០០៤)។ ប្រទេសចិនបានធ្វើកំណែទម្រង់លើវិស័យសហគ្រាសរដ្ឋ ការបើកឱ្យប្រទេសមានប្រព័ន្ធកំណត់តម្លៃទំនិញ (Pricing System) ការធ្វើឯកជនភាវូបនីយកម្ម ការកសាងហេដ្ឋារចនាសម្ព័ន្ធ និងការបង្កើតប្រព័ន្ធសុខមាលភាពសង្គម។

១៩៧៨-៨៤៖ ជារយៈពេលដែលបារម្ភពីគ្រោះអត់ឃ្លាន លោក តេង សៀវពីង បានអនុវត្តគោលនយោបាយប្រព័ន្ធថ្លៃពីរ (Dual Price System) ដោយអនុញ្ញាតិឱ្យសហគ្រាសរដ្ឋអាចលក់ផលិតផលលើសកូតាផែនការ និងតម្លៃអាចលក់បានតាមផែនការនិងទីផ្សារ។ ប្រទេសចិនបង្កើតតំបន់សេដ្ឋកិច្ចពិសេស និងអនុញ្ញាតឱ្យវិនិយោគក្រៅប្រទេសជាលើកដំបូង។ ពាណិជ្ជកម្មឯកជនត្រូវបានអនុញ្ញាតជាលើកដំបូង។

១៩៨៤-៩៣៖ នយោបាយកំណែទម្រង់របស់លោកតេងបន្តធ្វើ ដោយកាត់បន្ថយការគ្រប់គ្រងទៅលើវិស័យឯកជន និងចាប់ផ្តើមធ្វើឯកជនភាវូបនីយកម្មសហគ្រាសរដ្ឋ។ គាត់បានបើកឡើងវិញ សៀងហៃ Stock Exchange។ ក្នុងរយៈពេលនេះ សេដ្ឋកិច្ចមានការរីកចម្រើន ប៉ុន្តែចំណូលរបស់រដ្ឋបានបាត់បង់ច្រើន និងជួបបញ្ហាអតិផរណា។

១៩៩៣-២០០៥៖ ជារយៈពេលដែលមានការធ្វើឯកជនភាវូបនីយកម្មសហគ្រាសរដ្ឋក្នុងទ្រង់ទ្រាយធំ។ លោកតេង បានធ្វើកំណែទម្រង់ស៊ីជម្រៅ ដោយបានដាក់ឱ្យចូលនិវត្តមន្ត្រីដែលមានគំនិតអភិរក្សមួយចំនួន។ ចំនួននៃសហគ្រាសរដ្ឋបានធ្លាក់ចុះ៤៨% ដោយសារឯកជនភាវូបនីយកម្ម។ លោក JiangZeminដែលបន្តតំណែងពីលោក តេង បានបន្តកំណែទម្រង់ទៅលើវិស័យធនាគារ កាត់បន្ថយពន្ធ ដែលជារបាំងនៃការធ្វើពាណិជ្ជកម្ម។

២០០៥-២០១២៖ ជារយៈពេលដែលលោក Hu Jintao បានកែសម្រួលកំណែទម្រង់សេដ្ឋកិច្ចចិនរបស់លោក តេង សៀវពីង។ កំណែងទម្រង់បានផ្ដល់ Subsidy ដល់វិស័យសុខាភិបាល និងបានបង្កើនគោលនយោបាយរូបិយវត្ថុ ដែលអាចបង្កើតឱ្យមាន Bubble។

**២.២- កំណែទម្រង់សេដ្ឋកិច្ចទីផ្សារសេរីរបស់ចិននាពេលបច្ចុប្បន្ន**

ប្រទេសចិនដោយសារប្រើសេដ្ឋកិច្ចផែនការបានធ្វើឱ្យមានការផលិតលើស (OverCapacity Production)។ ហេតុដូចនេះ កំណែទម្រង់ទៅរកទីផ្សារសេរី ដែលផលិតតាមតម្រូវការទីផ្សារជាក់ស្ដែង។

ការដឹកនាំផលិតដោយរដ្ឋ (Government-oriented Resource Allocation) បានបណ្ដាលឱ្យមានហានិភ័យផ្នែកសេដ្ឋកិច្ចដូចជា ការផលិតលើស កើនបំណុលរដ្ឋាភិបាលតំបន់ បញ្ហាបរិស្ថាន និងទំនាស់ដីធ្លី។

ដូចនេះវិធានការដែលប្រទេសចិននឹងអនុវត្តមានដូចជា៖

- លុបបំបាត់ភាពផ្ដាច់មុខ (Monopoly)
- លុបបំបាត់ការដាក់កម្រិតលើការកំណត់ថ្លៃ (Price Control)
- លុបបំបាត់ការអន្តរាគមពីរដ្ឋ
- លុបបំបាត់ការបែងចែកទីផ្សារ (Market Partition) និងបង្រួមទីផ្សារឱ្យនៅតែមួយ។

**២.៣- កត្តាចូលរួមកំណើនពីកម្លាំងពលកម្ម មូលធន Total Factor of Production**




ប្រភព៖ https://www.forbes.com/sites/peterpham/2018/03/06/is-there-a-secret-growth-hormone-added-to-chinas-economy/#5490f4d03f13

កត្តាកំណើនសេដ្ឋកិច្ចរបស់ចិន គឺបណ្ដាលមកពីការវិនិយោគយ៉ាងសម្បើមលើមូលនិធិ (Capital) (ដោយគាំទ្រដោយការសន្សំក្នុងស្រុក (Saving) និងការវិនិយោគក្រៅប្រទេស) និងការកើនឡើងនៃផលិតភាព (Productivity Growth) ( W. Morison, ២០១៨)។

រូបភាពខាងលើបង្ហាញពីកត្តាដែលជាធាតុចូលក្នុងកំណើនសេដ្ឋកិច្ចចិន មាន Capital (សម្ភារៈរោងចក្រ និងបរិក្ខារ) បានចូលរួមក្នុងកំណើនជាងពាក់កណ្តាល កត្តាកំណើនផលិតភាពសរុប (Total Factor Productivity ដែលជាកត្តាចូលរួមកំណើនក្រៅពី កម្លាំងពលកម្ម និង មូលធន( Capital)) បានចូលរួមប្រមាណ១ភាគ៣ និង កត្តាកម្លាំងពលកម្មបានរួញចុះដែលកត្តានេះសំខាន់ពេលចាប់ផ្តើមដំបូង។ កត្តាកំណើនផលិតភាពសរុបមានដូចជា ប្រសិទ្ធភាពនៃផលិតភាពនៃផលិតកម្ម (Production efficiency and intensity)។

## ២.៤- គោលនយោបាយឧស្សាហកម្មត្រូវបានគាំទ្រដោយកម្លាំងពលកម្មរាប់រយលាននាក់

បើនិយាយពីចំនួនប្រជាជន ប្រទេសចិនជាប្រទេសដែលមានចំនួនប្រជាជនច្រើនជាងគេលើពិភពលោក ដែលជាកត្តាឱ្យប្រទេសចិនសម្បូរកម្លាំងពលកម្ម។ សព្វថ្ងៃនេះប្រទេសចិនមានកម្លាំងពលកម្ម (អាយុ១៥ដល់៦៤ ឆ្នាំ) មានចំនួន១ពាន់លាននាក់។ ជាដំបូងនៅក្នុងសេដ្ឋកិច្ចមុនឧស្សាហកម្ម កម្លាំងពលកម្មភាគច្រើននៅតំបន់កសិកម្ម។ ដោយប្រទេសចិនយកការអភិវឌ្ឍសេដ្ឋកិច្ចតាម Asian Capital Development model កសិករភាគច្រើន បានក្លាយជាកម្មករនៅរោងចក្រ ប៉ុន្តែជំនាញរបស់កម្មករទាំងមិនទាន់បានខ្ពស់នៅឡើយ ប៉ុន្តែមានលក្ខណៈប្រពលភាព (Intensive)។

## ២.៥- ការអភិវឌ្ឍវិស័យធនធានមនុស្ស និងការកើនឡើងផលិតភាព




ប្រភព៖ https://www.forbes.com/sites/peterpham/2018/03/06/is-there-a-secret-growth-hormone-added-to-chinas-economy/#5490f4d03f13

យើងឃើញថានិស្សិតចិនរាប់លាននាក់បានសិក្សាក្នុងសាកលវិទ្យាល័យ និងជាច្រើនបាននិងកំពុងសិក្សានៅក្រៅប្រទេស។ (Z. Xiaodong, ២០១២) បានឱ្យដឹងថា ការរីកចម្រើនរបស់សេដ្ឋកិច្ចចិន គឺបណ្តាលមកពីកើនឡើងផលិតភាព ដែលបណ្តាលមកពីការកើនឡើងនៃធនធានមនុស្ស។

### ២.៦- ប្រទេសចិនបានចម្លងការផលិតផលិតផលពីប្រទេសមហាអំណាចសេដ្ឋកិច្ច

នៅដើមទសវត្សរ៍ឆ្នាំ២០០០ ប្រទេសចិនបានក្លាយខ្លួនរួចហើយ ជាទីតាំងនៃការផលិតទំនិញរបស់ពិភពលោក។ ក្រោយពីរៀនសូត្រពីបច្ចេកវិទ្យា (Copy) របស់ជប៉ុននិងអាម៉េរិក ប្រទេសចិនអាចផលិតទំនិញទំនើបៗ ដូចជាគ្រឿងអេឡិចត្រូនិក និងឧស្សាហកម្មធន់ធ្ងន់។ ឥឡូវនេះ សហរដ្ឋអាម៉េរិកបានទាមទារឱ្យចិនគោរពកម្មសិទ្ធិបញ្ញា។

## ៣- ការរីចម្រើនសេដ្ឋកិច្ចចិន

### ៣.១- កំណើននិងស្ថានភាពសេដ្ឋកិច្ចរបស់ចិន

ក្នុងបរិបទនៃសាកលភាវូបនីយកម្ម ចិនបានបើកចំហរសេដ្ឋកិច្ចដែលបានធ្វើឱ្យសេដ្ឋកិច្ចរបស់ខ្លួនរីកចម្រើន ដែលអាចប្រកួតប្រជែងក្នុងពិភពលោក ហើយបានក្លាយជាសេដ្ឋកិច្ចដែលមានទំហំលេខ២ក្នុងពិភពលោក។

**តារាងទី១. ចំណាត់ថ្នាក់ GDP ប្រទេសក្នុងពិភពលោកឆ្នាំ២០១៦**

| ចំណាត់ថ្នាក់ | ប្រទេស | GDP (លាន$) | ភាគរយ |
|---|---|---|---|
| ពិភពលោក | | 75,212,696 | 100% |
| 1 | សហរដ្ឋអាម៉េរិក | 18,561,930 | 25% |
| សហភាពអឺរ៉ុប | | 17,110,523 | 23% |
| 2 | ចិន | 11,391,619 | 15% |
| 3 | ជប៉ុន | 4,730,300 | 6% |
| 4 | អាល្លឺម៉ង់ | 3,494,900 | 5% |
| 5 | អង់គ្លេស | 2,649,890 | 4% |
| 6 | បារាំង | 2,488,280 | 3% |
| 7 | ឥណ្ឌា | 2,250,990 | 3% |

(ប្រភព៖ IMF)

ក្រោយពីការបើកកំណែទម្រង់ឆ្នាំ១៩៧៨មក ប្រទេសចិនបានអភិវឌ្ឍសេដ្ឋកិច្ចរបស់ខ្លួនឱ្យរីកចម្រើន ទំហំសេដ្ឋកិច្ចរបស់ខ្លួនលេខ២ តាំងតែឆ្នាំ២០១១មកម្ល៉េះ។ នៅឆ្នាំ២០១៦ សេដ្ឋកិច្ចរបស់ប្រទេសចិនមានចំនួន១១ទ្រីលានដុល្លារ ដែលត្រូវជា១៥%នៃទំហំសេដ្ឋកិច្ចរបស់ពិភពលោក។




(ប្រភព៖ World Bank)




យើងឃើញថា បំណែងចែកផលិតផលជាតិសរុបរបស់ចិនក្នុងឆ្នាំ២០១៣ ក្នុងនោះកសិកម្មនៅសល់តែ ១០% ឧស្សាហកម្មមានចំនួន៤៤៥ និងសេវាកម្មមានចំនួណ៤៦%។ រូបភាពខាងក្រោមបានបង្ហាញថា ប្រទេសចិនមានកំណើនសេដ្ឋកិច្ចជាមធ្យមពី៧% ទៅ ១០%។

### ៣.២- ពាណិជ្ជកម្មរបស់ចិន

**តារាងទី២. ពាណិជ្ជកម្មរបស់ចិន និងពិភពលោក**

| | ការនាំចេញ | | នាំចូល | | Balance |
|---|---|---|---|---|---|
| | តម្លៃ (លាន$) | កំណើន | តម្លៃ (លាន$) | កំណើន | (លាន$) |
| 2007 | 1,021,896 | | 802,403 | | 219,492 |
| 2008 | 1,117,215 | 9.3% | 885,031 | 10.3% | 232,184 |
| 2009 | 991,078 | -11.3% | 827,701 | -6.5% | 163,377 |

| | | | | | |
|---|---|---|---|---|---|
| 2010 | 1,369,248 | 38.2% | 1,209,170 | 46.1% | 160,078 |
| 2011 | 1,569,090 | 14.6% | 1,438,681 | 19.0% | 130,409 |
| 2012 | 1,834,999 | 16.9% | 1,626,670 | 13.1% | 208,328 |
| 2013 | 1,914,210 | 4.3% | 1,687,896 | 3.8% | 226,313 |
| 2014 | 2,028,382 | 6.0% | 1,699,339 | 0.7% | 329,043 |
| 2015 | 2,363,787 | 16.5% | 1,660,230 | -2.3% | 703,557 |
| 2016 | 2,219,789 | -6.1% | 1,651,349 | -0.5% | 568,439 |
| 2017 | 2,321,066 | 4.6% | 1,865,048 | 12.9% | 456,018 |

( ប្រភព៖ European Commission )

យោងតាមរបាយការណ៍របស់ European Commission បានឱ្យដឹងថា ក្នុងឆ្នាំ២០១៧ប្រទេសចិន មានការនាំចេញសរុប ២,៣ ទ្រីលានដុល្លារ និងការនាំចូលប្រមាណ ១,៨ ទ្រីលានដុល្លារ។ ហេតុដូចនេះប្រទេសចិន មានអតិរេកជញ្ជីងពាណិជ្ជកម្មប្រមាណ៤៥៦ពាន់លានដុល្លារ ដែលអាចឱ្យប្រទេសចិន ទទួលទុនបម្រុងជាដុល្លារបន្ថែមយ៉ាងច្រើន ដែលសព្វថ្ងៃទុនបម្រុងរបស់ចិនមានចំនួន ៣,១៧ ទ្រីលានដុល្លារ។

**តារាងទី៣. ដៃគូពាណិជ្ជកម្មរបស់ចិនឆ្នាំ២០១៧**

| ការនាំចេញ | | | | ការនាំចូល | | | |
|---|---|---|---|---|---|---|---|
| | ដៃគូ | តម្លៃ (លាន$) | % | | ដៃគូ | តម្លៃ (លាន$) | % |
| | ពិភពលោក | 2,321,066 | 100.0% | | ពិភពលោក | 1,865,048 | 100.0% |
| 1 | សហរដ្ឋអាម៉េរិក | 441,539 | 19.0% | 1 | EU 28 | 249,610 | 13.4% |
| 2 | EU 28 | 381,471 | 16.4% | 2 | កូរ៉េខាងត្បូង | 180,752 | 9.7% |
| 3 | ហុងកុង | 286,984 | 12.4% | 3 | ជប៉ុន | 168,752 | 9.0% |
| 4 | ជប៉ុន | 140,000 | 6.0% | 4 | តៃវ៉ាន់ | 158,145 | 8.5% |
| 5 | កូរ៉េខាងត្បូង | 104,894 | 4.5% | 5 | សហរដ្ឋអាម៉េរិក | 157,717 | 8.5% |

( ប្រភព៖ European Commission )

សម្រាប់ដៃគូពាណិជ្ជកម្មរបស់ចិនយើងឃើញថា ទីផ្សារសម្រាប់នាំចេញដ៏ធំបំផុតរបស់ចិនគឺ សហរដ្ឋអាម៉េរិក ដែលចិននាំចេញទៅអាម៉េរិក៤៤១ពាន់លានដុល្លារ ដែលត្រូវជា១៩% នៃការនាំចេញសរុបរបស់ខ្លួន។ ទីផ្សារផ្សេងទៀតមានសហភាពអឺរ៉ុបមានទីផ្សារ ១៦,៤% ហុងកុង ១២,៤% និងជប៉ុន ៦%។

សម្រាប់ការនាំចូល គឺសហភាពអឺរ៉ុបបាននាំចូលច្រើនជាងគេចូលចិន ប្រមាណ២៤៩ពាន់លានដុល្លារ ប្រមាណ ១៣,៤% នៃការនាំចូលសរុបរបស់ចិន។ សហរដ្ឋអាម៉េរិកនាំចូលចិន តែ១៥៧ពាន់លានដុល្លារ ដែលត្រូវជា ៨,៥% នៃការនាំចូលសរុបរបស់ចិន។ ហេតុដូចនេះ យើងឃើញថា ប្រទេសចិនបានធ្វើឱ្យសហរដ្ឋអាម៉េរិកមានឱនភាពពាណិជ្ជកម្មយ៉ាងសម្បើមជាមួយនឹងខ្លួន។ សហរដ្ឋអាម៉េរិក ថ្មីៗនេះលោកប្រធានាធិបតី ត្រាំ បានប្រើគោល

នយោបាយគាំពារនិយមជាមួយនឹងចិននិងពិភពលោក។ ប្រទេសចិនបានដឹងបញ្ហានេះ តាំងតែមុនវិបត្តិនេះបានកើតឡើង។ ចិនបាននិងកំពុងប្តូរគោលនយោបាយសេដ្ឋកិច្ចមកពឹងផ្អែកតម្រូវការក្នុងស្រុកវិញ។

**៣.៣- ការវិនិយោគក្រៅប្រទេសរបស់ចិន**

ប្រទេសចិនបានក្លាយជាប្រភពយ៉ាងសំខាន់សម្រាប់ការវិនិយោគពីក្រៅប្រទេស របស់ប្រទេសនានាក្នុងពិភពលោក។ ការវិនិយោគចេញក្រៅប្រទេសចិនបានចាប់ផ្តើមកើនឡើងពីឆ្នាំ២០០០ ដោយសារការបន្ធូបទបញ្ញត្តិទាក់ទងមូលនិធិហូរចេញក្រៅរបស់ចិន។

សម្រាប់ឆ្នាំ២០១៧ ជានិន្នាការពិភពលោក លំហូរវិនិយោគក្រៅប្រទេស (FDI) មានការថយចុះ ១៨% ដែលនៅក្នុងនោះ លំហូរវិនិយោគចូលសហរដ្ឋអាម៉េរិកធ្លាក់ចុះនៅត្រឹមតែ ២៨៧ពាន់លានដុល្លារ ដោយឆ្នាំ២០១៥ និង ២០១៦ មានចំនួនជាង ៤៥០ពាន់លានដុល្លារ។

សម្រាប់ឆ្នាំ២០១៦ ដោយយោងតាមរបាយការណ៍របស់ប្រទេស OECD ការវិនិយោគចេញក្រៅប្រទេសរបស់ចិន មានចំនួនរហូតដល់ ២១៧ពាន់លានដុល្លារ ដែលឈរលំដាប់លេខ២ នៃប្រទេសដែលមានការវិនិយោគចេញក្រៅប្រទេសច្រើនជាងគេក្នុងពិភពលោក។ យោងតាមសាព័ត៌មាន xihuanetរបស់ចិនបានឱ្យដឹងថា ការ វិនិយោគចេញក្រៅប្រទេសរបស់ចិនច្រើនជាងការវិនិយោគចូលក្នុងប្រទេសរបស់ចិនចំនួន ៣៦%។

យោងតាម លោក James Zhan (ប្រធាន UNCTAD's investment and enterprise division) បាននិយាយថា ការវិនិយោគចេញក្រៅប្រទេស ជាការគាំទ្រដល់គម្រោងខ្សែក្រវាត់និងវិថី និងការសហប្រតិបត្តិការអន្តរជាតិ។

យោងតាម China Investment Tracker ក្នុងឆ្នាំ២០១៧ អាស៊ីទទួល FDI ពីចិនចំនួន ៣១,៩ពាន់លានដុល្លារ ត្រូវជា ១៨,៨% អឺរ៉ុប FDI ចំនួន ៩០,៦ ពាន់លានដុល្លារ ត្រូវជា ៥៣,៤% ទ្វីបអាម៉េរិកខាងជើង FDI ពីចិនចំនួន ២៧,០ ពាន់លានដុល្លារ ត្រូវជា ១៦,០% និងអាហ្វ្រិកទទួល FDI ពីចិនចំនួន១,០ ពាន់លានដុល្លារ ត្រូវជា ០,៦%។




(ប្រភព៖ 2012 statistical Bulletin of China)

## ៤- សន្និដ្ឋាន

យើងឃើញថាសេដ្ឋកិច្ចចិនសព្វថ្ងៃ មានការរីកចម្រើនខ្លាំង ប៉ុន្តែកំណើនសេដ្ឋកិច្ចត្រូវបានគាំទ្រដោយការវិនិយោគសម្រាប់ការបង្កើនមូលនិធិ (Capital Stock Accumulation)។ យោងតាម Solow Model (១៩៥៨) សេដ្ឋកិច្ចមួយមិនអាចរីកកើនឡើងរហូតដោយពឹងលើកំណើន Capital Stock ដែលទប់ទល់ដោយកំណើន Saving ។ ជាក់ស្តែងសេដ្ឋកិច្ចជប៉ុនដែលពឹងផ្អែកលើកំណើន Capital Stock ដែលទប់ទល់ដោយកំណើន Saving បានធ្លាក់ចុះ កំណើននាពេលសព្វថ្ងៃ ដោយសារកំណើន Saving បានធ្លាក់ចុះ ដោយសារតែប្រជាជនភាគច្រើនបានក្លាយជាមនុស្សចាស់ (Aging Population)(I. Tomoyuki et al, ២០១៨)។ ការវិនិយោគរបស់ចិនបានឱ្យសញ្ញាធ្លាក់ចុះ ចាប់ពីឆ្នាំ ២០១២៕

## គន្ថនិទ្ទេស


- https://www.forbes.com/sites/peterpham/2018/03/06/is-there-a-secret-growth-hormone-added-to-chinas-economy/#5490f4d03f13
- *2012 statistical Bulletin of China*
- R. Minami, F. Makino (2005), *Economic Development in China*
- F. Chi (2014), *Decisive Role of the Market*, China Reform Research Report
- F. Chi(2012), *Consumption-Led Growth*, China Reform Research Report
- Osamu T (2015), *Economic Reform and Economic Policy of the Xi Jinping Leadership*, Policy Research Review
- European Commission (2018), *Trade in Goods with China.*
- https://www.ofx.com/en-au/forex-news/historical-exchange-rates/yearly-average-rates/
- W. M Morison (2018), *China's Economic Rise: History, Trends, Challenges, and Implications for the United States*, Congressional Research Seervice
- G. Chow (2004), *Economic Reform and Growth in China*, ANNALS OF ECONOMICS AND FINANCE 5, 127–152
- Xiaodong Zhu (2012), *Understanding China's Growth: Past, Present, and Future*, Journal of Economic Perspectives—Volume 26, Number 4
- I. Tomoyuki et al (2018), *What Drives China's Growth ? Evidence from Micro-level Data*, Bank of Japan